ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Apr-2019, 14:00
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
អនុស្សរណៈអន្តរការិយាល័យ

ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩

**ជូនចំពោះ៖** គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២
ការិយាល័យសហចៅក្រមស៊ើបអង្កេត
ចៅក្រមនៃអង្គបុរេជំនុំជម្រះ

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
ផ្នែករដ្ឋបាលតុលាការ

**កម្មវត្ថុ៖** ឯកសារសម្ងាត់នៅក្នុងសាលក្រមសំណុំរឿង ០០២/០២ ដែលស្នើសុំឲ្យមានការធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ

១. កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមនៃសំណុំរឿង ០០២/០២ និងបានសេចក្តីសង្ខេបសំអាងហេតុនៅក្នុងសវនាការជាសាធារណៈ (សូមមើលឯកសារ E1/529.1)។ សាលក្រមជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុពេញលេញ ត្រូវបានជូនដំណឹងជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ (សូមមើលឯកសារ E465)។

២. អង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណឯកសារសម្ងាត់ចំនួន **១.៤៣៩** ដែលខ្លឹមសារនៃឯកសារទាំងនេះត្រូវបានយកមកធ្វើជាសំអាង យោង ឬដកស្រង់នៅក្នុងសាលក្រម ដើម្បីធ្វើជាមូលដ្ឋាននៃការយល់ឃើញផ្នែកអង្គហេតុ និងអង្គច្បាប់ (សូមមើល**ឧបសម្ព័ន្ធ ក-ឃ**)។ បន្ទាប់ពីបានពិនិត្យមើលឯកសារទាំងនេះដូចមាននៅក្នុងឧបសម្ព័ន្ធ អង្គជំនុំជម្រះយល់ឃើញថា ចំណាត់ប្រភេទឯកសារទាំងនេះជាឯកសារសម្ងាត់លែងមានភាពចាំបាច់ទៀតហើយនៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។ ហេតុដូច្នេះ អង្គជំនុំជម្រះស្នើឲ្យមានការធ្វើចំណាត់ប្រភេទឯកសារទាំងនេះឡើងវិញជាឯកសារសាធារណៈ ស្របតាមមាត្រា

៩.១ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង (“សេចក្តីណែនាំអនុវត្ត”)។

៣. ក្នុងចំណោមឯកសារដែលត្រូវបានកំណត់អត្តសញ្ញាណទាំងនោះ មានឯកសារចំនួន ១.៣៣៨ គឺជាឯកសារភ័ស្តុតាងដែលបានដាក់អំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ (**ឧបសម្ព័ន្ធ ក**) និងឯកសារចំនួន ៨០ ជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ឬសារណា និងឯកសារគាំទ្រ ដែលជាមូលដ្ឋាននៃសេចក្តីសម្រេចជាសាធារណៈ ឬសេចក្តីសម្រេចជាសម្ងាត់របស់អង្គជំនុំជម្រះ ដែលស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឡើងវិញ នៅក្នុងឧបសម្ព័ន្ធ ក-ឃ (**ឧបសម្ព័ន្ធ ខ**)។ មាត្រា ៤ នៃសេចក្តីណែនាំអនុវត្តចែងថា ជាគោលការណ៍ ភ័ស្តុតាងដែលបានដាក់នៅក្នុងអំឡុងសវនាការជំនុំជម្រះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃសវនាការសាធារណៈ គឺជាឯកសារសាធារណៈ។ ហេតុនេះ អង្គជំនុំជម្រះស្នើសុំមតិយោបល់ពីភាគីពាក់ព័ន្ធទាំងអស់ អំពីភាពចាំបាច់ ឬមិនចាំបាច់ក្នុងការរក្សាឯកសារទាំងនេះជាឯកសារសម្ងាត់ជាបន្តទៀត នៅក្នុងដំណាក់កាលនេះនៃសំណុំរឿង ០០២/០២ ជាពិសេស ពាក់ព័ន្ធនឹងមាត្រា ៤.១(គ), (ឃ) និង (ង) នៃសេចក្តីណែនាំអនុវត្ត។

៤. ក្នុងចំណោមឯកសារដែលនៅសេសសល់ មានឯកសារចំនួន ១៩ ជាឯកសារដែលបានដាក់ដោយ ឬនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត នៅក្នុងអំឡុងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ (**ឧបសម្ព័ន្ធ គ**) ហើយឯកសារចំនួន ២ ទៀត យោងទៅជនរងគ្រោះដែលមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីតទៅទៀតទេក្នុងសំណុំរឿង ០០២ (**ឧបសម្ព័ន្ធ ឃ**)។ មាត្រា ៥ នៃសេចក្តីណែនាំអនុវត្តចែងថា ជាគោលការណ៍ ឯកសារបែបនេះគឺជាឯកសារសម្ងាត់ លើកលែងតែមានសេចក្តីសម្រេចធ្វើចំណាត់ប្រភេទឯកសារទាំងនេះឡើងវិញ។ ដូច្នេះ អង្គជំនុំជម្រះស្នើសុំមតិយោបល់ពីភាគីពាក់ព័ន្ធទាំងអស់ អំពីភាពចាំបាច់ ឬមិនចាំបាច់ក្នុងការរក្សាឯកសារទាំងនេះជាឯកសារសម្ងាត់ជាបន្តទៀត ក្នុងដំណាក់កាលនេះនៃសំណុំរឿង ០០២/០២ ជាពិសេស ពាក់ព័ន្ធនឹងមាត្រា ៥.១(ខ), (គ), (ឃ), (ង), (ច) និង (ឆ) នៃសេចក្តីណែនាំអនុវត្ត។

៥. នៅពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងមិនទាន់ស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឡើងវិញ ឬធ្វើចំណាត់ថ្នាក់ចំពោះឯកសារសម្ភារសម្ងាត់បំផុតនៅក្នុងសំណុំរឿងនៅឡើយទេ។

៦. អង្គជំនុំជម្រះស្នើសុំឱ្យភាគីពាក់ព័ន្ធទាំងអស់នៃអនុស្សរណៈនេះ ផ្តល់មតិយោបល់អំពីវិធានការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ដែលបានស្នើឡើងនៅក្នុងអនុស្សរណៈនេះ នៅត្រឹម**ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩**។ ប្រសិនបើអង្គជំនុំជម្រះមិនបានទទួលចម្លើយតបនៅត្រឹមកាលបរិច្ឆេទនេះទេ អង្គជំនុំជម្រះចាត់ទុកថាគ្មានការជំទាស់ឡើយ។